# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអបអរសាទរខួប៥៥ឆ្នាំរបស់ព្រះសហគមន៍សន្តមីកាអែល
# កំពង់សោម ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០
# រួមគ្នាសម្លាប់អំពើបាបដូចសន្តមីកាអែល

**អត្ថបទទី១៖ អេសេគីអែល ១៨,២៥-២៨**

ប្រសិនបើអ្នកនោះភ្ញាក់ស្មារតី ហើយលះបង់អំពើអាក្រក់ទាំងប៉ុន្មាន គេពិតជារស់រានមានជីវិត គឺគេមិនត្រូវស្លាប់ឡើយ។ អគ ១៨,២៨

**អត្ថបទទី២៖ ភីលីព ២,១-១១**

កុំធ្វើអ្វីដោយចង់ប្រកួតប្រជែងគ្នា ឬដោយអួតបំប៉ោងឡើយ ផ្ទុយទៅវិញ ត្រូវដាក់ខ្លួន ហើយចាត់ទុកអ្នកឯទៀតៗថា ប្រសើរជាងខ្លួន។ ភីល ២,៣

**ដំណឹងល្អ៖ ម៉ាថាយ ២១,២៨-៣២**

ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា ពួកអ្នកទារពន្ធ និងពួកស្ត្រីពេស្យា នឹងចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់មុនអ្នករាល់គ្នា។ មថ ២១,៣១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ដែលយើងអបអរសាទរខួប៥៥ឆ្នាំរបស់ព្រះសហគមន៍សន្តមីកាអែល ជាពិសេស ៥៥ឆ្នាំដែលយើងបានកសាងព្រះវិហារកំពង់សោមនេះ។ នៅឆ្នាំ១៩៦៥ មានលោកឪពុកម្នាក់ឈ្មោះ អាដូបេរី (MEP) គាត់ជាបូជាចារ្យទទួលខុសត្រូវនៅកំពត គាត់ពូកែគូរនិងរចនាអាគារ ហើយគាត់បានសហការជាមួយវិស្វករដ៏ល្បីបំផុតនៅប្រទេសកម្ពុជា គឺលោកតា ម៉ូលីវ៉ាន់ (ដែលបានសាងសង់ផ្សារធំថ្មី សាលមហោរស្រពចតុមុខ...) ដើម្បីសាងសង់ព្រះវិហារនេះ។ នៅសម័យនោះព្រះវិហារទូទៅ គឺគេសាងសង់ដូចនៅអឺរ៉ុប (ព្រះវិហារភ្នំបូកគោ) នៅគ្រប់ខេត្ត ប៉ុន្តែនៅក្រុងព្រះសីហនុគេបានសាងសង់ព្រះវិហារមួយប្លែក ដោយសារទាំងលោកឪពុកអាដូបេរី ទាំងលោកតាម៉ូលីវ៉ាន់ ចង់សាងសង់អាគារមួយទំនើប។ ពេលយើងមើលព្រះវិហារនេះ មិនមែនរូបរាងជាព្រះវិហារទេ តែមានរាងជាសំពៅដែលមានក្តោងយ៉ាងធំដើម្បីណែនាំឲ្យយើងធ្វើដំណើរលើសមុទ្រ។ ហេតុនេះហើយ នៅសម័យប៉ុលពតព្រះវិហារនេះគេមិនបានវាយចោល ដោយសារគេមិនដឹងថាជាព្រះវិហារ គេគិតថាជាអាគារមួយដែលនៅជិតមាត់សមុទ្រអាចធ្វើជាបន្ទាយទាហានបាន។

អរព្រះគុណព្រះជាម្ចាស់ ដែលបានណែនាំឲ្យព្រះវិហារនេះទៅជាសាក្សីនៃប្រវត្តិសាស្ត្រព្រះសហគមន៍កាតូលិកកម្ពុជា ពីឆ្នាំ១៩៦៥ ដែលជាសម័យសង្គមរាស្ត្រនិយម រហូតដល់ឆ្នាំ១៩៧០ ដែលយើងចូលនៅក្នុងសម័យ លុន នល់ និងសង្គ្រាមស៊ីវិល ឆ្នាំ១៩៧៥ សម័យប៉ុលពត ឆ្នាំ១៩៧៩ សម័យវៀតណាម ឆ្នាំ១៩៩៣ សម័យអ៊ុនតាក់ និងសម័យបច្ចុប្បន្ន។ ដូច្នេះ ព្រះវិហារ

នេះបានឃើញច្រើនណាស់ ថ្ងៃនេះយើងមិននឹកឃើញអាគារនៃព្រះវិហាររបស់យើង ប៉ុន្តែនឹកឃើញអំពីព្រះសហគមន៍ដែលជួបជុំគ្នានៅក្នុងព្រះវិហារ ព្រះសហគមន៍ជាក្រុមគ្រីស្តបរិស័ទដែលព្រះជាម្ចាស់ត្រាស់ហៅឲ្យចូលនៅក្នុងព្រះវិហារ ដើម្បីអធិដ្ឋាន ដើម្បីអរព្រះគុណព្រះជាម្ចាស់។ ព្រះសហគមន៍ជាស្ថាបនដែលមានអាយុជាង២០០០ឆ្នាំ ព្រះសហគមន៍ជាស្ថាបនមួយដែលស្ថិតស្ថេរជានិច្ច ពីក្រុមគ្រីស្តទូតយើងបានបន្តជំនឿដើម្បីឲ្យមានគ្រីស្តបរិស័ទជាច្រើនជំនាន់ អាចរួមរស់ធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទនៅទីក្រុងព្រះសីហនុ ក៏ដូចជានៅក្នុងមណ្ឌលសកម្មភាពកំពង់សោម ជាឱកាសមួយដើម្បីពិចារណា **តើយើងជាគ្រីស្តបរិស័ទ យើងធ្វើដូចម្តេចដើម្បីចូលនៅក្នុងប្រវត្តិសាស្រ្ត នៃព្រះសហគមន៍របស់យើង ៥៥ឆ្នាំកន្លងមក?** ដែលបានឆ្លងទុកលំបាក ដែលបានឆ្លងអំណរសប្បាយ ដែលបានចូលនៅក្នុងប្រវត្តិសាស្រ្តថ្មី ដោយសារក្រុងព្រះសីហនុទៅជាទីក្រុងថ្មីមែនទែន។ ណែនាំឲ្យយើងយល់ថា នៅក្នុងដៃរបស់យើង ដោយសាងសង់លើមូលដ្ឋានគ្រឹះពីអតីតកាលយើងកំពុងរៀបចំអនាគត ដោយយកចិត្តទុកដាក់នៅក្នុងបច្ចុប្បន្ននេះ ដើម្បីធ្វើជាគ្រីស្តបរិស័ទដ៏ពិសេស។

យើងមានអគ្គទេវទូតបីគឺ មីកាអែល រ៉ាហ្វាអែល និងកាព្រីអែល។ សន្តមីកាអែល មានលំពែងមួយដែលកំពុងវាយមារសាតាំង ដោយសារគាត់ជានិមិត្តរូបនៃអំពើល្អនិងអំពើសុចរិតដែលសម្លាប់អំពើបាប អំពើអាក្រក់ អំពើទុច្ចរិត។ ខ្មែរយើងក៏មានមីកាអែលដែរ គឺហនុមាន ជាស្វាដែលយកចិត្តទុកដាក់ប្រព្រឹត្តអំពើល្អ និងសម្លាប់យ័ក្សដែលជាអំពើអាក្រក់។ ម្យ៉ាងទៀតយើងមាន គ្រុឌ ដែលបានសម្លាប់អំពើអាក្រក់ ពេលយើងបញ្ចូលសត្វទាំងពីរនេះយើងទទួលបានមីកាអែលមួយ ជាអ្នកបម្រើ ធ្វើអំពើល្អ ដើម្បីសម្លាប់អំពើអាក្រក់។ សម្រាប់យើងថ្ងៃនេះ ដែលយើងបានស្តាប់អត្ថបទគម្ពីរដំណឹងល្អដែលនិយាយអំពី "**កូនប្រុសពីរនាក់**" ដែលកូនពៅថាខ្លួនទៅធ្វើចម្ការក្រោយមកគាត់មិនទៅ កូនច្បងគាត់បដិសេធក្រោយមកគាត់ទៅ ហើយព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំសូមប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាប់ថាពួកអ្នកទារពន្ធ និងពួកស្ត្រីពេស្យា នឹងចូលទៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់មុនអ្នករាល់គ្នា**"។ នេះដោយសារគេសុខចិត្តកែប្រែចិត្តគំនិត កូនច្បងដែលមានគំនិតបដិសេធបានកែប្រែចិត្តគំនិត ដោយយល់ថានៅពេលគាត់បដិសេធណែនាំឲ្យឪពុកគាត់ពិបាកចិត្ត។ ហេតុនេះហើយ គាត់បានពិចារណានិងបានឯកភាពដើម្បីឲ្យឪពុកគាត់ពោរពេញដោយសេចក្តីសុខ។

ថ្ងៃនេះ តាមរយៈអគ្គទេវទូតមីកាអែល ឲ្យយើងមើលជីវិតរបស់យើង ជាពេលវេលាមួយដើម្បីសាងសង់ជីវិតថ្មី។ ជួនកាលយើងដូចកូនពៅ ដែលបានចូលគ្រប់សកម្មភាពរបស់ព្រះសហគមន៍ ក្រោយមកយើងចោលលែងចូលក្នុងក្រុមណាមួយរបស់ព្រះសហគមន៍ ណែនាំឲ្យយើង

ភ្លេចខ្លួនអស់ហើយ។ ប៉ុន្តែ តាមរយៈសន្តមីកាអែលដែលជាឧបការីនៃព្រះសហគមន៍របស់យើង យើងត្រូវការភ្ញាក់ស្មារតីសាជាថ្មីដើម្បីគិត អត្ថន័យមីកាអែលជាភាសាខ្មែរដែលមានន័យថា "**ព្រះជាម្ចាស់ជានរណា?**" នេះជាសំណួរមួយដែលយើងទាំងអស់គ្នាត្រូវតែសួរគ្រប់ពេលវេលា **សម្រាប់ខ្ញុំព្រះជាម្ចាស់ជានរណា?** នេះជាសំណួរដែលព្រះយេស៊ូបានសួរដល់ក្រុមគ្រីស្តទូតពីដើម សម្រាប់មហាជនខ្ញុំជានរណា? ជាព្យាការីម្នាក់ ជាអេលី ជាអេសាយ...។ ក្រោយមកព្រះយេស៊ូបានថែមថា សម្រាប់បងប្អូនខ្ញុំជានរណា? លោកសិលាបានឆ្លើយថាលោកជាព្រះបុត្រារបស់ព្រះជាម្ចាស់។ សម្រាប់យើងទាំងអស់គ្នា ពេលយើងមើលឃើញរូបសន្តមីកាអែលឲ្យយើងគិត **ព្រះជាម្ចាស់ជានរណា? តើព្រះជាម្ចាស់នៅកន្លែងណា?** តើព្រះជាម្ចាស់នៅក្នុងអាគារខ្ពស់ៗដែលយើងកំពុងសាងសង់? តើព្រះជាម្ចាស់នៅក្នុងកាស៊ីណូដែលបានដុះដូចផ្សិតនៅទីក្រុងយើង? តើព្រះជាម្ចាស់នៅក្នុងកប៉ាល់អន្តរជាតិដែលមកពីប្រទេសនានា? តើព្រះជាម្ចាស់នៅក្នុងព្រះវិហារយើង? កុំឲ្យយើងវិនិច្ឆ័យលឿនពេក កុំឲ្យយើងឆ្លើយលឿនពេកថាគ្មានព្រះជាម្ចាស់នៅក្នុងកាស៊ីណូ គ្មាននៅក្នុងអាគារខ្ពស់ៗ គ្មាននៅក្នុងកប៉ាល់អន្តរជាតិ គឺព្រះជាម្ចាស់នៅក្នុងព្រះវិហារ។ កុំឲ្យយើងធ្វើដូចគណៈផារីស៊ីដែលគិតថាមានតែគេដែលមានព្រះជាម្ចាស់ ហើយគិតថាអ្នកដទៃជាមនុស្សបាប។ ប៉ុន្តែព្រះយេស៊ូមានព្រះបន្ទូលថ្ងៃនេះ ជាអ្នកទារពន្ធ ជាអ្នកដែលលេងល្បែងស៊ីសង ជាស្ត្រីពេស្យាដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីធ្វើជាមនុស្សថ្មី និងដើម្បីទៅជាអ្នកដែលទទួលវត្តមានព្រះជាម្ចាស់នៅក្នុងដួងចិត្ត។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទឲ្យយើងធ្វើប្រយ័ត្ន ដើម្បីឆ្លើយថាពិតមែនព្រះជាម្ចាស់គង់នៅទីនេះ ព្រះជាម្ចាស់គង់នៅក្នុងការអធិដ្ឋានរបស់យើងដែលចេញពីដួងចិត្ត។ ព្រះជាម្ចាស់នៅក្នុងដួងចិត្តរបស់យើងជាមនុស្សបាប ដែលសុខចិត្តកែប្រែចិត្តគំនិត ព្រះជាម្ចាស់គង់នៅក្នុងស្នាដៃធម៌មេត្តាករុណាដែលបង្ហាញអំពីវត្តមានរបស់ព្រះអង្គនៅក្នុងពិភពលោកនេះ។ ទេវទូតកាព្រីអែលមានតួនាទីមួយកាត់ក្តីយើង ហើយសម្រេចឲ្យយើងទៅស្ថានបរមសុខឬយើងត្រូវចុះនៅស្ថានក្រោម។ ដូច្នេះ កុំឲ្យយើងនិយាយថានៅក្នុងអាគារថ្មី នៅក្នុងកាស៊ីណូ នៅក្នុងកប៉ាល់អន្តរជាតិសុទ្ធតែមនុស្សអាក្រក់ មនុស្សមិនល្អ ឲ្យយើងមើលខ្លួនឯងសិនដោយគិតថាយើងផ្ទាល់យើងត្រូវតែបង្ហាញវត្តមានរបស់ព្រះជាម្ចាស់នៅទីនេះ។ យើងត្រូវការផ្តល់សក្ខីភាពនៅក្នុងបច្ចុប្បន្នថ្មីនេះដើម្បីរៀបចំអនាគត យើងត្រូវការមានចិត្តមេត្តាករុណាដូចសន្តវ៉ាំងសង់ឌឺប៉ូល ដែលជានិមិត្តរូបនៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់នៅក្នុងសង្គម៣០០ឆ្នាំមុន។ យើងមានសិទ្ធិកែប្រែចិត្តគំនិត ប៉ុន្តែឲ្យយើងកែប្រែចិត្តពីបដិសេធទៅឯកភាពដើរជាមួយព្រះជាម្ចាស់តទៅទៀត។

នៅក្នុងអត្ថបទទីពីរ យើងមានអ្វីៗទាំងអស់ដើម្បីរួមរស់ជាគ្រីស្តបរិស័ទដែលបង្ហាញវត្តមានរបស់ព្រះជាម្ចាស់សម្រាប់បងប្អូនឯទៀតៗ។ ព្រះជាម្ចាស់ជានរណា ស៊ីសងលើយើងឲ្យមានចិត្តមេត្តាករុណា **"ប្រសិនបើបងប្អូនពិតជាមានចិត្តអាណិតអាសូរ និងចិត្តមេត្តាករុណាមែននោះ សូមធ្វើឲ្យខ្ញុំមានអំណរសប្បាយ បងប្អូនមានចិត្តគំនិតតែមួយ មានសេចក្តីស្រឡាញ់តែមួយ មានចិត្តថ្លើមតែមួយ មានឆន្ទះតែមួយ ត្រូវដាក់ខ្លួនហើយចាត់ទុកអ្នកឯទៀតៗថា ប្រសើរជាងខ្លួន"** កុំឲ្យយើងពោរពេញដោយអំនួត។ ប្រសិនបើយើងថែរក្សា ចិត្តមេត្តាករុណា ចិត្តថ្លើមតែមួយនៅក្នុងព្រះសហគមន៍ដែលជាមហាគ្រួសាររបស់ព្រះជាម្ចាស់ ប្រសិនបើយើងដាក់ខ្លួនកុំឲ្យយើងពោរពេញដោយអំនួត ណែនាំឲ្យយើងអាចបង្កើតព្រះសហគមន៍ដែលបង្ហាញវត្តមានរបស់ព្រះជាម្ចាស់បាន។ នេះជាតួនាទីរបស់យើង ដើម្បីមើលជីវិតរបស់យើងផ្ទាល់ទៅជាមនុស្សថ្មី និងដើម្បីណែនាំឲ្យបងប្អូនឯទៀតៗអាចរកឃើញវត្តមានរបស់ព្រះជាម្ចាស់ តាមរយៈព្រះសហគមន៍របស់យើង តាមរយៈជីវិតរបស់យើងផ្ទាល់។

ថ្ងៃនេះយើងមានបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីចូលជាសមាជិកថ្មីក្នុងមហាគ្រួសាររបស់យើង និងមានបងប្អូនមួយចំនួនទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត យើងដឹងថាគ្រួសាររបស់យើងបន្តិចម្តងៗរីកចម្រើន។ ថ្ងៃនេះ យើងអធិដ្ឋានតាមរយៈសន្តមីកាអែល ឲ្យយើងអាចបង្កើតព្រះសហគមន៍ដ៏មានជីវិត ព្រះសហគមន៍ដែលជាស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅលើផែនដីនេះ នៅក្នុងធម៌មេត្តាករុណាជានិច្ច។ យើងអធិដ្ឋាទូលអង្វរ ឲ្យសន្តមីកាអែលអធិដ្ឋានសម្រាប់យើងដែលជាអ្នកមានបាបដើម្បីឲ្យយើងធ្វើជាមនុស្សថ្មី ឲ្យយើងរួមរស់ជាមួយព្រះយេស៊ូបង្កើតព្រះសហគមន៍នៅក្នុងមណ្ឌលសកម្មភាពកំពង់សោម នៅក្រុងព្រះសីហនុយើងនៅទីនេះ៕ អាម៉ែន៕